អគ្គនាយកដ្ឋានពន្ធដារ

GENERAL DEPARTMENT OF TAXATION

# ផែនការយុទ្ធសាស្ត្រ

## ២០២៤ - ២០២៨

បោះពុម្ព ឆ្នាំ២០២៤

# មាតិកា

ទំព័រ


**អារម្ភកថា** ............................................................ i

**សេចក្ដីផ្ដើម** ............................................................ ១

**ផ្នែកទី១៖ ទស្សនវិស័យ បេសកកម្ម និងគុណតម្លៃ** .................... ៣

**ផ្នែកទី២៖ គោលបំណង និងគោលដៅជាយុទ្ធសាស្ត្រ**........................ ៥

គោលបំណងទី១៖ បង្កើនអនុលោមភាពសារពើពន្ធ តាមរយៈការលើកកម្ពស់គុណភាព ភាពច្បាស់លាស់ តម្លាភាព និងគណនេយ្យភាព ក្នុងការផ្ដល់សេវានិងការអនុវត្តបទប្បញ្ញត្តិស្ដីពីពន្ធដារ........................ ៥

គោលដៅទី១៖ ផ្ដល់សេវាជូនអ្នកជាប់ពន្ធឱ្យកាន់តែមានភាពសាមញ្ញ រហ័ស ងាយស្រួល និងគ្រប់ជ្រុងជ្រោយ........................ ៦

គោលដៅទី២៖ ពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្ដីពីពន្ធដារប្រកបដោយភាពទន់ភ្លន់ តែម៉ឺងម៉ាត់ ស្មើភាព និងជឿទុកចិត្តបាន ........................ ៨

គោលបំណងទី២៖ បន្តធ្វើបរិវត្តកម្មឌីជីថលរដ្ឋបាលសារពើពន្ធ ដើម្បីក្លាយជារដ្ឋបាលសារពើពន្ធ ២.០ បូក ........................ ៩

គោលដៅទី១៖ បន្តធ្វើទំនើបកម្មលើហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ........................ ៩

គោលដៅទី២៖ ពង្រឹងសន្តិសុខបច្ចេកវិទ្យាព័ត៌មាន ដើម្បីធានានិរន្តរភាពរដ្ឋបាលសារពើពន្ធឌីជីថល .. ១០

គោលបំណងទី៣៖ បន្តអភិវឌ្ឍមូលធនមនុស្ស និងពង្រឹងប្រសិទ្ធភាពការងារ ........................ ១០

គោលដៅទី១៖ ពង្រឹងប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការគ្រប់គ្រងធនធានមនុស្ស........................ ១០

គោលដៅទី២៖ ពង្រឹងប្រសិទ្ធភាព និងសង្គតិភាពការងារ តាមរយៈសវនកម្មផ្ទៃក្នុង ........................ ១១

គោលដៅទី៣៖ ពង្រឹងប្រសិទ្ធភាព និងតម្លាភាពនៃការចំណាយឱ្យស្របតាមផែនការយុទ្ធសាស្ត្រថវិកា........................ ១២

**ផ្នែកទី៣៖ សេចក្ដីសន្និដ្ឋាន** ........................ ១៥



# អារម្ភកថា

## ឯកឧត្តម គង់ វិបុល

### រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី
### ប្រតិភូរាជរដ្ឋាភិបាល
### ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ

ក្នុងគោលបំណងចូលរួមអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រកែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល ស្របតាមគោលការណ៍អភិបាលកិច្ច និងរដ្ឋបាលកិច្ចល្អ និងក្រឹត្យក្រមវិជ្ជាជីវៈនៃការដឹកនាំ និងគ្រប់គ្រងស្ថាប័ន/អង្គភាពបែបយុទ្ធសាស្ត្រ (Strategic Leadership and Management) ចាប់ពីឆ្នាំ២០១៩មក អគ្គនាយកដ្ឋានពន្ធដារបានរៀបចំ និងដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រ (Strategic Plan) និងផែនការប្រតិបត្តិ (Operational Plan) ២០១៩-២០២៣ ដែលមានលក្ខណៈប្រទាក់ក្រឡាច្បាស់លាស់ជាខ្នាតឧត្តមានុវត្តន៍អន្តរជាតិ។ សូមបញ្ជាក់ថា ផែនការយុទ្ធសាស្ត្រ គឺជាផែនការមេ និងជាផែនទីតម្រង់ទិសទៅមុខរបស់ស្ថាប័ន/អង្គភាព សម្រាប់រយៈពេលមធ្យម ឬរយៈពេលវែង ដែលក្នុងនោះមានរំលេចសេចក្តីថ្លែង **ទស្សនវិស័យ បេសកកម្ម គុណតម្លៃ គោលបំណង និងគោលដៅជាយុទ្ធសាស្ត្រ** របស់ស្ថាប័ន/អង្គភាព សម្រាប់បំបែកចេញជាផែនការប្រតិបត្តិកម្រិតក្បោះក្បាយដើម្បីអនុវត្តដាក់ស្តែងប្រចាំថ្ងៃ។

ផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិដំណាក់កាលទី១ របស់អគ្គនាយកដ្ឋានពន្ធដារ ២០១៩-២០២៣ ដែលបានរៀបចំឡើង ស្របតាមទិសដៅរបស់យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤ ដែលមាន "អភិបាលកិច្ច" ជាស្នូលយុទ្ធសាស្ត្រ និង "កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ" និង "យុទ្ធសាស្ត្រកៀរគរចំណូល" ២០១៩-២០២៣ ដែលបាននិងកំពុងអនុវត្តប្រកបដោយជោគជ័យ ទាំងកម្មវិធីកែទម្រង់ធ្វើបរិវត្តកម្មឱ្យទៅជារដ្ឋបាលសារពើពន្ធទំនើបទាន់សម័យ ទាំងការគ្រប់គ្រងប្រមូលចំណូលពន្ធបង់ចូលថវិកាជាតិ លើសផែនការដែលកំណត់ដោយច្បាប់ជាបន្តបន្ទាប់ពីមួយឆ្នាំទៅមួយឆ្នាំ។ ជាលទ្ធផល ក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយនេះ ការប្រមូលចំណូលពន្ធក្នុងស្រុក មានការកើនឡើងគួរឱ្យកត់សម្គាល់ដោយលទ្ធផលនៃការប្រមូលចំណូលរក្សាបាននូវកំណើនចីរភាពចំណូល ក្នុងរង្វង់ជាមធ្យមប្រមាណ ១៨% ក្នុងមួយឆ្នាំ ដោយសម្រេចបាន ១២៣,២០% ក្នុងឆ្នាំ ២០១៩, ១០១,៣៦% ក្នុងឆ្នាំ២០២០, ១២៤,០២% ក្នុងឆ្នាំ២០២១, ១២២,៥៤% ក្នុងឆ្នាំ២០២២ និង ១០១,១៣% ក្នុង

ឆ្នាំ២០២៣។ លទ្ធផលដ៏ត្រចះត្រចង់នេះ កើតចេញពីការខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំនៃអគ្គនាយកដ្ឋានពន្ធដារ ក៏ដូចជាមន្ត្រីរាជការពន្ធដារគ្រប់លំដាប់ថ្នាក់ក្នុងការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងនីតិកាលទី៦ នៃរដ្ឋសភា ព្រមទាំងការចង្អុលបង្ហាញដោយផ្ទាល់ និងជាប្រចាំរបស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**។

ការរៀបចំដាក់ឱ្យអនុវត្តនូវផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិរបស់អគ្គនាយកដ្ឋានពន្ធដារដំណាក់កាលទី២ ២០២៤-២០២៨ គឺជាការបន្តអនុវត្តកម្មវិធីកែទម្រង់ស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ដែលបានដាក់ឱ្យអនុវត្តសម្រាប់នីតិកាលទី៧ នៃរដ្ឋសភា រាជរដ្ឋាភិបាលក្រោមការដឹកនាំពោរពេញដោយសមត្ថភាព ថាមពល ទេពកោសល្យ គុណធម៌ សីលធម៌ និងបញ្ញាញាណដ៏ឆ្នើមរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។ សូមបញ្ជាក់ថាការបន្តកែទម្រង់ **អភិបាលកិច្ច** ដែលជាស្នូលនៃយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី១-ទី៤ នៅតែបន្តជាស្នូលនៃយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១។ ក្នុងចំណោមគោលដៅយុទ្ធសាស្ត្រសំខាន់ៗរបស់យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ គឺក្លាយជារដ្ឋាភិបាលឌីជីថលនៅឆ្នាំ២០៣៥ ដោយគ្រប់ស្ថាប័នរដ្ឋទាំងអស់ត្រូវតែជាស្ថាប័នឌីជីថល។ សម្រាប់អគ្គនាយកដ្ឋានពន្ធដារ និន្នាការនេះ គឺស្របតាមគោលដៅយុទ្ធសាស្ត្ររួមរបស់រដ្ឋបាលសារពើពន្ធក្នុងតំបន់ និងពិភពលោកស្តីពីការធ្វើបរិវត្តកម្មរដ្ឋបាលពន្ធដារជំនាន់ទី៣.០ (Tax Administration 3.0) ហើយដែលគោលបំណងចម្បងៗ នៅក្នុងផែនការយុទ្ធសាស្ត្រ ២០២៤-២០២៨ របស់អគ្គនាយកដ្ឋានពន្ធដារ គឺ៖ (១) បង្កើនអនុលោមភាពសារពើពន្ធ តាមរយៈការលើកកម្ពស់គុណភាព ភាពច្បាស់លាស់ តម្លាភាព និងគណនេយ្យភាព ក្នុងការផ្តល់សេវានិងការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ (២) បន្តធ្វើបរិវត្តកម្មឌីជីថលរដ្ឋបាលសារពើពន្ធ ដើម្បីក្លាយជារដ្ឋបាលសារពើពន្ធ ២.០ បូក និង (៣) បន្តអភិវឌ្ឍមូលធនមនុស្ស និងពង្រឹងប្រសិទ្ធភាពការងារ។ ជារួម គោលបំណងទាំង៣ចំណុចខាងលើ គឺផ្តោតទៅលើការធ្វើបរិវត្តកម្មអគ្គនាយកដ្ឋានពន្ធដារឱ្យទៅជារដ្ឋបាលសារពើពន្ធឌីជីថល ឬរដ្ឋបាលសារពើពន្ធជំនាន់ទី៣.០ ដើម្បីបង្កើនសមត្ថភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពក្នុងការគ្រប់គ្រងការប្រមូលចំណូលពន្ធប្រកបដោយនិរន្តរភាព។

ខ្ញុំសូមជំរុញឱ្យគ្រប់នាយកដ្ឋានថ្នាក់កណ្តាល សាខាពន្ធដារខេត្ត-ខណ្ឌ និងមន្ត្រីពន្ធដារគ្រប់លំដាប់ថ្នាក់ចូលរួមអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិ ២០២៤-២០២៨ របស់អគ្គនាយកដ្ឋានពន្ធដារ និងចូលរួមសហការអនុវត្តឱ្យបានជោគជ័យជាបន្តបន្ទាប់ ស្របតាមពេលវេលាដែលបានកំណត់។

កត្តាសំខាន់មួយទៀត ក្នុងដំណើរការនៃការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិនេះ ក៏ដូចជាក្នុងដំណើរការនៃការបំពេញភារកិច្ចការងារប្រចាំថ្ងៃ មន្ត្រីគ្រប់លំដាប់ថ្នាក់ត្រូវប្រកាន់ឱ្យបានខ្ជាប់ខ្ជួននូវអភិក្រមការងាររបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** "ឆ្លុះកញ្ចក់ ងូតទឹក ដុះក្អែល ព្យាបាល និងវះកាត់", អភិក្រមការងាររបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** "គ្មានការធ្វើកំណែទម្រង់ណាមួយដែលងាយស្រួលនោះទេ កំណែទម្រង់ដែលជោគជ័យផ្អែកលើកត្តាសំខាន់ៗបួន៖ (១) ចក្ខុវិស័យច្បាស់លាស់ (២) ការប្តេជ្ញាចិត្តខ្ពស់ (៣) ការចូលរួមដោយស្មោះត្រង់ និង (៤) ការលះបង់", និងអភិក្រមការងារ

៤ប្រការរបស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** រួមមាន៖ (១) អនុវត្តការងារប្រកបដោយវិជ្ជាជីវៈ និងគោរពក្រមសីលធម៌វិជ្ជាជីវៈ (២) អនុវត្តការងារជាក្រុម (៣) អនុវត្តការងារដោយប្រកាន់ខ្ជាប់នូវស្មារតីបុរេសកម្ម និងគោលការណ៍ប្រសិទ្ធភាពថវិកា និង (៤) មិនត្រូវមើលរំលងកំហុសខ្លួនឯង។

ថ្ងៃចន្ទ ១៤កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០២៤

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**

**ប្រតិភូរាជរដ្ឋាភិបាល**

**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**

# សេចក្តីផ្តើម

ក្នុងក្របខ័ណ្ឌនៃការអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ ស្របតាមគោលនយោបាយកំណែទម្រង់ស៊ីជម្រៅ និងមុតស្រួចរបស់រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា អគ្គនាយកដ្ឋានពន្ធដារបានផ្តោតជាចម្បងលើការកែទម្រង់គោលនយោបាយសារពើពន្ធ និងរដ្ឋបាលសារពើពន្ធតាមរយៈការធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធនិងពង្រឹងអភិបាលកិច្ចល្អលើមុខងារស្នូលនិងមុខងារគាំទ្រ ព្រមទាំងបំពេញភារកិច្ចនិងបេសកកម្មប្រកបដោយវិជ្ជាជីវៈនិងក្រមសីលធម៌ ដើម្បីបង្កើនប្រសិទ្ធភាព ស័ក្តិសិទ្ធិភាពក្នុងការប្រមូលចំណូលពន្ធក្នុងស្រុក។ ជាលទ្ធផល ក្នុងរយៈពេលចុងក្រោយនេះ អគ្គនាយកដ្ឋានពន្ធដារបានប្រមូលចំណូលពន្ធ-អាករសម្រេចបានលើសផែនការ ដែលកំណត់ដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំនីមួយៗ រហូតដល់មានឆ្នាំខ្លះទទួលបានសន្ទុស្សន៍កំណើន២ខ្ទង់ ទោះបីជាកម្ពុជានិងសកលលោក ទទួលរងនូវផលប៉ះពាល់ពីវិបត្តិដែលបណ្តាលមកពីការរីករាលដាលនៃជំងឺកូវីដ-១៩ និងសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន ក៏ដោយ។ សមិទ្ធផលទាំងនេះកើតចេញពីការចូលរួមយ៉ាងសកម្មរបស់មន្ត្រីរាជការពន្ធដារគ្រប់លំដាប់ថ្នាក់ ក្រោមការគាំទ្រ ការណែនាំ និងការចង្អុលបង្ហាញពីប្រមុខរាជរដ្ឋាភិបាល និងថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ទោះជាយ៉ាងណាក៏ដោយ ដើម្បីបន្តចូលរួមរក្សាបាននូវចីរភាពថវិកាឱ្យស្របតាមការកើនឡើងឥតឈប់ឈរនៃតម្រូវការថវិកាជាតិ ដើម្បីបន្តធានាស្ថិរភាពសេដ្ឋកិច្ច និងបន្តជំរុញកំណើនសេដ្ឋកិច្ច អគ្គនាយកដ្ឋានពន្ធដារត្រូវតែបង្កើនការយកចិត្តទុកដាក់និងខិតខំពុះពារបន្ថែមទៀត ក្នុងការដាក់ចេញនិងអនុវត្តន៍នូវវិធានការជាយុទ្ធសាស្ត្ររបស់ខ្លួន។

ផែនការយុទ្ធសាស្ត្រ ២០២៤-២០២៨ របស់អគ្គនាយកដ្ឋានពន្ធដារនេះ ត្រូវបានរៀបចំស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល។ ផែនការយុទ្ធសាស្ត្រនេះ ចែកចេញជា ៣ផ្នែកសំខាន់ៗគឺ៖ **ផ្នែកទី១-ទស្សនវិស័យ បេសកកម្ម និងគុណតម្លៃ ផ្នែកទី២-គោលបំណង និងគោលដៅជាយុទ្ធសាស្ត្រ** និង**ផ្នែកទី៣-សេចក្តីសន្និដ្ឋាន**។

# ផ្នែកទី១
# ទស្សនវិស័យ បេសកកម្ម និងគុណតម្លៃ

អគ្គនាយកដ្ឋានពន្ធដារ បំពេញការងារក្នុងក្របខ័ណ្ឌនៃទស្សនវិស័យ បេសកកម្ម និងគុណតម្លៃ ដូចតទៅ៖

## ទស្សនវិស័យ

ជាស្ថាប័នសាធារណៈដែលត្រូវបានជឿជាក់ គោរព និងទទួលស្គាល់លើគុណភាពនិងជំនាញ ក្នុងការប្រមូលចំណូលពន្ធក្នុងស្រុក ដើម្បីចូលរួមអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព។

## បេសកកម្ម

ពង្រឹងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ និងផ្តល់សេវាប្រកបដោយស័ក្តិសិទ្ធិភាព តម្លាភាព គណនេយ្យភាព និងសុចរិតភាព ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការប្រមូលចំណូលពន្ធ និងលើកកម្ពស់អនុលោមភាពដោយស្ម័គ្រចិត្ត។

## គុណតម្លៃ

**ការអនុវត្ត** ៖ អនុវត្តច្បាប់ គាំទ្រអ្នកជាប់ពន្ធដែលមានអនុលោមភាព តែម៉ឺងម៉ាត់ចំពោះអ្នកជាប់ពន្ធដែលមិនមានអនុលោមភាព

**វិជ្ជាជីវៈ** ៖ ប្រើប្រាស់ក្រមសីលធម៌វិជ្ជាជីវៈ និងជំនាញ ដើម្បីផ្តល់នូវសេវាដែលមានភាពសាមញ្ញ ងាយស្រួល ឆ្លាតវៃ និងនវានុវត្តន៍

**ស័ក្តិសិទ្ធិភាព** ៖ ប្រើប្រាស់ធនធាន ដោយសន្សំសំចៃ ទាន់ពេលវេលា និងចំគោលដៅ

**សុចរិតភាព** ៖ ផ្តល់សេវាជូនអ្នកជាប់ពន្ធ ដោយស្មើភាព តម្លាភាព និងស្អាតស្អំ

**ភាពបត់បែន** ៖ ឆ្លើយតបយ៉ាងសកម្មទៅនឹងបញ្ហាប្រឈម និងទាញយកប្រយោជន៍ពីគ្រប់ឱកាសដែលមាន។

# ផ្នែកទី២
# គោលបំណង និងគោលដៅយុទ្ធសាស្ត្រ

១. បង្កើនអនុលោមភាពសារពើពន្ធ តាមរយៈ: ការលើកកម្ពស់គុណភាព ភាពច្បាស់លាស់ តម្លាភាព និងគណនេយ្យភាព ក្នុងការផ្តល់សេវា និង ការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ

២. បន្តធ្វើបរិវត្តកម្មឌីជីថលរដ្ឋបាលសារពើពន្ធ ដើម្បីក្លាយជារដ្ឋបាលសារពើពន្ធ ២.0 បូក

៣. បន្តអភិវឌ្ឍមូលធនមនុស្ស និងពង្រឹងប្រសិទ្ធភាពការងារ

## គោលបំណងទី១៖ បង្កើនអនុលោមភាពសារពើពន្ធ តាមរយៈ:ការលើកកម្ពស់គុណភាព ភាពច្បាស់លាស់ តម្លាភាព និងគណនេយ្យភាព ក្នុងការផ្តល់សេវានិងការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ

ដើម្បីបន្តធានាបាននូវនិរន្តរភាពនៃការប្រមូលចំណូលពន្ធក្នុងស្រុក ឱ្យស្របតាមការកើនឡើងឥតឈប់ឈរនៃតម្រូវការថវិកាជាតិ ក៏ដូចជាការឆ្លើយតបទៅនឹងបរិការណ៍សង្គម-សេដ្ឋកិច្ចឌីជីថល អគ្គនាយកដ្ឋានពន្ធដារនឹងបន្តបង្កើនការយកចិត្តទុកដាក់បន្ថែមទៀត ក្នុងការរិះរកនិងផ្តួចផ្តើមដាក់ចេញនូវវិធានការដែលមានប្រសិទ្ធភាពខ្ពស់ក្នុងការផ្តល់សេវាប្រកបដោយគុណភាពជូនអ្នកជាប់ពន្ធ ដើម្បីកាត់បន្ថយបន្ទុកចំណាយលើការបំពេញកាតព្វកិច្ចនិងនីតិវិធីសារពើពន្ធ និងបន្តពង្រឹងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារជាធរមាន តាមការអនុវត្តស្មើភាពចំពោះអ្នកជាប់ពន្ធ ដើម្បីបង្កើនការប្រកួតប្រជែងដោយស្មើភាព និងលើកកម្ពស់វប្បធម៌នៃការបង់ពន្ធ។ ដើម្បីសម្រេចគោលបំណងនេះ អគ្គនាយកដ្ឋានពន្ធដារបានកំណត់គោលដៅដូចខាងក្រោម៖

## គោលដៅទី១៖ ផ្ដល់សេវាជូនអ្នកជាប់ពន្ធឱ្យកាន់តែមានភាពសាមញ្ញ រហ័ស ងាយស្រួល និងគ្រប់ជ្រុងជ្រោយ

សម្រាប់រយៈពេល ៥ឆ្នាំចុងក្រោយនេះ អគ្គនាយកដ្ឋានពន្ធដារបានសម្រេចនូវសមិទ្ធផលជាច្រើនក្នុងការផ្ដល់សេវាប្រកបដោយគុណភាពជូនដល់អ្នកជាប់ពន្ធ ក្នុងគោលដៅបង្កើនអនុលោមភាពសារពើពន្ធដោយស្ម័គ្រចិត្ត និងកាត់បន្ថយជាអតិបរមានូវបន្ទុករបស់អ្នកជាប់ពន្ធ។ ជាក់ស្ដែង អគ្គនាយកដ្ឋានពន្ធដារបានដាក់ឱ្យដំណើរការនូវការចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ប្រព័ន្ធគ្រប់គ្រងការចុះបញ្ជីសហគ្រាស ប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មតាមអនឡាញ (e-Filing for Tax Declaration) ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (Tax on Income - ToI e-Filing) ប្រព័ន្ធគ្រប់គ្រងបង់ប្រាក់ពន្ធតាមអនឡាញ (e-Payment System) កម្មវិធីប្រកាសពន្ធអាជីវកម្មសម្រាប់អ្នកជាប់ពន្ធតូច (GDT Tax Prefiling App) កម្មវិធីទូរស័ព្ទដៃត្រួតពិនិត្យ និងតាមដានឯកសារ (GDT Check & Track App) ប្រព័ន្ធគ្រប់គ្រងទិន្នន័យអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក (e-Commerce Tax System) ប្រព័ន្ធគ្រប់គ្រងការស្នើសុំវិញ្ញាបនបត្រពន្ធដារ (Tax Certificate Management System) ប្រព័ន្ធគ្រប់គ្រងពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិយានជំនិះតាមអនឡាញ (Online Tax on Vehicle Transferring System) ប្រព័ន្ធគ្រប់គ្រងការសិក្សាពន្ធដារ (Tax Learning Management System) ប្រព័ន្ធគ្រប់គ្រងការស្នើសុំការលើកទឹកចិត្ត (Incentive Request Management System) ប្រព័ន្ធគ្រប់គ្រងការស្នើសុំចៀសវាងការយកពន្ធត្រួតគ្នា (Double Taxation Avoidance) កម្មវិធីទូរស័ព្ទដៃអ្នកជាប់ពន្ធ (GDT Taxpayer App) សម្រាប់ការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូននិងពន្ធលើអចលនទ្រព្យ និងការដាក់ឱ្យដំណើរការប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងកម្មវិធីសម្រាប់ទូរស័ព្ទដៃ (Mobile Apps) ជាច្រើនទៀត។

ជាមួយគ្នានេះ ដើម្បីធានាការផ្ដល់ព័ត៌មានជូនអ្នកជាប់ពន្ធឱ្យមានសង្គតិភាពនិងឯកភាព សេវាអប់រំ និងផ្សព្វផ្សាយបញ្ញាបវេជ្ជធម៌នៃការបង់ពន្ធត្រូវបានធ្វើឡើងយ៉ាងសកម្ម និងទូលំទូលាយ តាមគ្រប់មធ្យោបាយទាំងដោយផ្ទាល់ និងទាំងតាមប្រព័ន្ធអេឡិចត្រូនិក ដូចជា ការបើកវគ្គបណ្ដុះបណ្ដាល សិក្ខាសាលា កម្មវិធី "ពន្ធដារកម្ពុជា (GDT Cambodia)" ការឆ្លើយសំណួរនិងការផ្ដល់សេវាជូនអ្នកជាប់ពន្ធតាមមជ្ឈមណ្ឌលពិគ្រោះយោបល់តាមទូរស័ព្ទ (GDT Call Center) កម្មវិធីជជែកផ្ទាល់ជាមួយពន្ធដារ (GDT Live Chat App) ប្រអប់សំបុត្រ បណ្ដាញសង្គម ឬធ្វើឡើងដោយផ្ទាល់មាត់តាមរយៈបញ្ជរពិគ្រោះយោបល់ វីដេអូ រួមទាំងការបោះពុម្ពផ្សាយសៀវភៅណែនាំ និងខិត្តប័ណ្ណស្ដីពីប្រភេទពន្ធនីមួយៗ និងការដាក់ឱ្យដំណើរការកម្មវិធីសទ្ទានុក្រមពន្ធដារ (Tax Glossary App)។

បន្ថែមលើយន្តការខាងលើ អគ្គនាយកដ្ឋានពន្ធដារតែងតែយកចិត្តទុកដាក់លើកង្វល់នានារបស់អ្នកជាប់ពន្ធ និងបានចូលរួមយ៉ាងយកចិត្តទុកដាក់ក្នុងការធ្វើឱ្យប្រសើរឡើងនូវបរិយាកាសធុរកិច្ច និងវិនិយោគ តាមរយៈការជួយសម្រួលផ្ដល់សេវាឆាប់រហ័សជូនអ្នកជាប់ពន្ធនិងសាធារណជនទូទៅ និងការចូលរួមយ៉ាងសកម្មក្នុងការលើកកម្ពស់ភាពជាដៃគូបានរឹងមាំជាមួយវិស័យឯកជន ដូចជាវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន និងយន្តការភាពជាដៃគូនានា។

ទន្ទឹមនឹងការខិតខំបង្កើនគុណភាពសេវាជូនអ្នកជាប់ពន្ធ អគ្គនាយកដ្ឋានពន្ធដារ ក៏បានចូលរួមគិតគូរ រៀបចំគោលនយោបាយស្ដីពីសារពើពន្ធ និងធ្វើឱ្យប្រសើរឡើងនូវលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងពន្ធដារ ដើម្បីផ្ដល់

តម្លាភាព និងភាពងាយស្រួលក្នុងការឈ្វេងយល់អំពីសិទ្ធិ និងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ លើកកម្ពស់ក្នុងការបំពេញអនុលោមភាពសារពើពន្ធ។ ជាក់ស្ដែង អគ្គនាយកដ្ឋានពន្ធដារសម្រេចបាននូវការរៀបចំចងក្រងច្បាប់ស្ដីពីសារពើពន្ធឆ្នាំ២០២៣ ដែលធានាបាននូវភាពប្រទាក់ក្រឡាគ្នាជាមួយនឹងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន និងជាការធ្វើបច្ចុប្បន្នភាពច្បាប់នេះឱ្យឆ្លើយតបនឹងការរីកចម្រើននៃសង្គម-សេដ្ឋកិច្ច។

ទោះបីជាអគ្គនាយកដ្ឋានពន្ធដារបានខិតខំផ្តល់សេវាជូនអ្នកជាប់ពន្ធ និងអនុវត្តគោលនយោបាយនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងពន្ធដារ ដូចមានរៀបរាប់ខាងលើក៏ដោយ ក៏ការលើកកម្ពស់គុណភាពសេវា ក៏ដូចជាការគិតគូរលើការរៀបចំគោលនយោបាយសារពើពន្ធបន្ថែមទៀត នៅតែត្រូវបានចាត់ទុកថាជាគោលបំណងអាទិភាពបំផុត ដើម្បីចូលរួមកាត់បន្ថយបន្ទុកនិងកសាងទំនុកចិត្តជូនអ្នកជាប់ពន្ធនៅក្នុងបរិការណ៍នៃការវិវត្តសេដ្ឋកិច្ច និងសង្គមឌីជីថល។ ដើម្បីសម្រេចគោលដៅនេះ អគ្គនាយកដ្ឋានពន្ធដារ បានដាក់ចេញនូវយុទ្ធសាស្ត្រដូចខាងក្រោម៖

- យុទ្ធសាស្ត្រទី១៖ លើកកម្ពស់ការផ្តល់សេវាកម្មបច្ចេកវិទ្យាព័ត៌មាន ឱ្យស្របតាមការវិវត្តនៃបរិបទធុរកិច្ច
- យុទ្ធសាស្ត្រទី២៖ លើកកម្ពស់វប្បធម៌ នៃការបង់ពន្ធតាមរយៈការផ្តល់សេវាបណ្តុះបណ្តាល និងផ្សព្វផ្សាយគោលនយោបាយ និងបទប្បញ្ញត្តិស្តីពីពន្ធដារ
- យុទ្ធសាស្ត្រទី៣៖ លើកកម្ពស់ការឆ្លើយតបរាល់ចម្ងល់ និងបញ្ហាផ្សេងៗរបស់អ្នកជាប់ពន្ធ ឱ្យមានការឯកភាពគ្នា
- យុទ្ធសាស្ត្រទី៤៖ លើកកម្ពស់ការផ្តល់សេវាប្រកបដោយគុណភាពតាមរយៈការរៀបចំផែនការយុទ្ធសាស្ត្រសេវាអ្នកជាប់ពន្ធ
- យុទ្ធសាស្ត្រទី៥៖ លើកកម្ពស់ភាពជាដៃគូជាមួយវិស័យឯកជន និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធនានា
- យុទ្ធសាស្ត្រទី៦៖ កំណត់តម្រូវការ និងភាពពេញចិត្តរបស់អ្នកជាប់ពន្ធ ចំពោះការផ្តល់សេវារបស់អគ្គនាយកដ្ឋានពន្ធដារ
- យុទ្ធសាស្ត្រទី៧៖ លើកកម្ពស់បរិយាកាសពន្ធដារតាមរយៈការចូលរួមរៀបចំ និងអនុវត្តគោលនយោបាយ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងពន្ធដារ

## គោលដៅទី២៖ ពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ ប្រកបដោយភាពទន់ភ្លន់ តែម៉ឺងម៉ាត់ ស្មើភាព និងជឿទុកចិត្តបាន

កន្លងមក អគ្គនាយកដ្ឋានពន្ធដារបានរៀបចំឯកសារវិភាគហានិភ័យទូទៅ និងបានកែលម្អជាបន្តបន្ទាប់នូវវិធីសាស្ត្រកំណត់ហានិភ័យរបស់អ្នកជាប់ពន្ធ ដោយបានធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។ ទន្ទឹមនឹងនេះ អគ្គនាយកដ្ឋានពន្ធដារបានរៀបចំនិងដាក់ឱ្យអនុវត្តនូវវិធានការរដ្ឋបាល និងការកែទម្រង់គោលនយោបាយសារពើពន្ធ ដើម្បីធានាបាននូវការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដោយស្មើភាព តម្លាភាព និងសមធម៌ក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធ។ ជាក់ស្តែង អគ្គនាយកដ្ឋានពន្ធដារបានកសាងនូវទិន្នន័យសំខាន់ជាសារវន្ត សម្រាប់ផ្ទៀងផ្ទាត់ការបំពេញកាតព្វកិច្ចរបស់អ្នកជាប់ពន្ធតាមរយៈប្រព័ន្ធទិន្នន័យដែលទទួលបានពីការចុះបញ្ជីនិងការធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ ការដាក់លិខិតប្រកាសពន្ធ ការធ្វើសវនកម្មពន្ធដារ ការគ្រប់គ្រងបំណុលពន្ធ ការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ក៏ដូចជាការពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូក្នុងការចែករំលែកព័ត៌មានជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ និងដៃគូអន្តរជាតិ។

យ៉ាងណាមិញ ឯកសារវិភាគហានិភ័យទូទៅរបស់អគ្គនាយកដ្ឋានពន្ធដារនាពេលបច្ចុប្បន្ននៅមានភាពចង្អៀត មិនទាន់គ្រប់ជ្រុងជ្រោយនិងស៊ីជម្រៅ ដែលទាមទារឱ្យមានការកែសម្រួលនិងធ្វើឱ្យប្រសើរឡើងស្របតាមស្តង់ដាអន្តរជាតិ។ ដូចនេះ អគ្គនាយកដ្ឋានពន្ធដារត្រូវបន្តជ្រើសរើសវិធីសាស្ត្រសមស្របក្នុងការកំណត់ហានិភ័យ ដើម្បីធ្វើឱ្យប្រសើរឡើងនូវឯកសារវិភាគហានិភ័យទូទៅរបស់រដ្ឋបាលសារពើពន្ធ ឱ្យស្របតាមឧត្តមានុវត្តន៍អន្តរជាតិ ដែលជួយដល់ការលើកកម្ពស់ប្រសិទ្ធភាពមុខងារស្នូល ក៏ដូចជាដំណើរការដោយស្វ័យប្រវត្តិក្នុងការគ្រប់គ្រង និងប្រមូលពន្ធ ឱ្យមានប្រសិទ្ធភាព ចំគោលដៅ និងទាន់ពេលវេលា។ លើសពីនេះ ឥរិយាបថរបស់អ្នកជាប់ពន្ធមួយចំនួនក្នុងការព្យាយាមគេចវេះពន្ធ និងកិបកេងបន្លំពន្ធបង្កឱ្យមានការប្រកួតប្រជែងមិនស្មើភាព និងប៉ះពាល់ដល់សមធម៌ក្នុងការបង់ពន្ធ។ ហេតុនេះ អគ្គនាយកដ្ឋានពន្ធដារ បានដាក់ចេញនូវយុទ្ធសាស្ត្រដូចខាងក្រោម៖

យុទ្ធសាស្ត្រទី១៖ ធ្វើឱ្យប្រសើរឡើងនូវឯកសារវិភាគហានិភ័យទូទៅរបស់រដ្ឋបាលសារពើពន្ធ ឱ្យស្របតាមឧត្តមានុវត្តន៍អន្តរជាតិ

យុទ្ធសាស្ត្រទី២៖ ធ្វើឱ្យប្រសើរឡើងនូវបរិយាកាសប្រកួតប្រជែងដោយស្មើភាពតាមរយៈការពង្រឹងប្រសិទ្ធភាពមុខងារស្នូលរបស់រដ្ឋបាលសារពើពន្ធ

## គោលបំណងទី២៖ បន្តធ្វើបរិវត្តកម្មឌីជីថលរដ្ឋបាលសារពើពន្ធ ដើម្បីក្លាយជារដ្ឋបាលសារពើពន្ធ ២.០ បូក

ស្របតាមនិន្នាការវិវត្តន៍របស់រដ្ឋបាលសារពើពន្ធក្នុងតំបន់ និងសកល ឆ្ពោះទៅជារដ្ឋបាលសារពើពន្ធឌីជីថល ដោយមានការប្រែប្រួលឥតឈប់ឈរនៃបច្ចេកវិទ្យា ភាពរីកចម្រើននៃសេដ្ឋកិច្ច-សង្គមឌីជីថល និងភាពចាំបាច់ក្នុងការកែទម្រង់រដ្ឋបាលសារពើពន្ធស្របតាមគោលការណ៍អភិបាលកិច្ច និងរដ្ឋបាលកិច្ចល្អ អគ្គនាយកដ្ឋានពន្ធដារកំពុងចាប់យកឱកាសទាំងនោះ ក្នុងការបន្តធ្វើបរិវត្តកម្មឌីជីថលរដ្ឋបាលសារពើពន្ធ ដើម្បីក្លាយជារដ្ឋបាលសារពើពន្ធ ២.០ បូក សម្រាប់គាំទ្រដល់ការប្រមូលចំណូលពន្ធដារ និងលើកកម្ពស់គុណភាពសេវាជូនអ្នកជាប់ពន្ធ។ ដើម្បីឈានទៅជារដ្ឋបាលសារពើពន្ធ ២.០ បូក អគ្គនាយកដ្ឋានពន្ធដារ បានកំណត់គោលដៅដូចខាងក្រោម៖

### គោលដៅទី១៖ បន្តធ្វើទំនើបកម្មលើហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន ត្រូវបានចាត់ទុកថាជាមូលដ្ឋានគ្រឹះចាំបាច់នៃដំណើរការប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។ ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលជាអាទិ៍មាន៖ មជ្ឈមណ្ឌលទិន្នន័យ សេវូបករណ៍ ឧបករណ៍ផ្ទុកទិន្នន័យ ឧបករណ៍បច្ចេកវិទ្យាសម្រាប់អ្នកប្រើប្រាស់ បណ្ដាញតភ្ជាប់ និងអ៊ីនធឺណិត ដែលជាផ្នែករឹងនិងទន់សម្រាប់ប្រើប្រាស់ក្នុងការគាំទ្រដល់ដំណើរការនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។ ដោយឡែក ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ត្រូវបានប្រើប្រាស់សម្រាប់គាំទ្រដល់ប្រតិបត្តិការមុខងារស្នូល និងមុខងារគាំទ្រ។

អគ្គនាយកដ្ឋានពន្ធដារ បានកសាងនិងដាក់ឱ្យប្រើប្រាស់នូវហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីធ្វើទំនើបភាវូបនីយកម្មនិងបរិវត្តកម្មឌីជីថលរដ្ឋបាលសារពើពន្ធកម្ពុជា និងចូលរួមក្នុងការពង្រឹងអភិបាលកិច្ចល្អ និងរដ្ឋបាលកិច្ចល្អ។ ជាលទ្ធផល អគ្គនាយកដ្ឋានពន្ធដារត្រូវបានចាត់ទុកជាស្ថាប័នសាធារណៈដែលមានសមត្ថភាពក្នុងការចាប់យកបច្ចេកវិទ្យាឌីជីថលកម្រិតខ្ពស់ សម្រាប់គ្រប់គ្រងស្ថាប័ន និងផ្ដល់សេវាជូនអ្នកជាប់ពន្ធ។ ដោយសារកិច្ចខិតខំប្រឹងប្រែងរបស់អគ្គនាយកដ្ឋានពន្ធដារ ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលមានការកើនឡើងសម្រាប់រដ្ឋបាលសារពើពន្ធ អ្នកជាប់ពន្ធ និងស្ថាប័នពាក់ព័ន្ធដទៃទៀត។ ដោយនិន្នាការវិវត្តន៍នៃសង្គមសេដ្ឋកិច្ចឌីជីថល និងការប្រែក្លាយជារដ្ឋបាលសារពើពន្ធ ២.០ បូក ដើម្បីបង្កើនអនុលោមភាពសារពើពន្ធ លើកកម្ពស់គុណភាពសេវា និងពង្រឹងការអនុវត្តបទប្បញ្ញត្តិស្ដីពីពន្ធដារ អគ្គនាយកដ្ឋានពន្ធដារបានដាក់ចេញនូវយុទ្ធសាស្ត្រដូចខាងក្រោម៖

យុទ្ធសាស្ត្រទី១៖ បន្តពង្រឹងការគ្រប់គ្រង អភិវឌ្ឍន៍ និងធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន

យុទ្ធសាស្ត្រទី២៖ បន្តអភិវឌ្ឍ និងធ្វើបច្ចុប្បន្នភាពប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

## គោលដៅទី២៖ ពង្រឹងសន្តិសុខបច្ចេកវិទ្យាព័ត៌មាន ដើម្បីធានានិរន្តរភាពរដ្ឋបាលសារពើពន្ធឌីជីថល

ស្ថិតក្នុងបរិការណ៍នៃបរិវត្តកម្មឌីជីថល ទាំងវិស័យសាធារណៈនិងឯកជន បាននិងកំពុងផ្តល់អាទិភាពលើការធ្វើបរិវត្តកម្មឌីជីថលនៅក្នុងស្ថាប័នរបស់ខ្លួន ដើម្បីធានាឱ្យបាននូវនិរន្តរភាព ប្រសិទ្ធភាព ភាពរីកចម្រើន និងភាពប្រកួតប្រជែង។ ការធានាបាននូវសន្តិសុខបច្ចេកវិទ្យាព័ត៌មានដ៏រឹងមាំ គឺពិតជាមានភាពចាំបាច់បំផុតក្នុងការចៀសវាងនិងបង្ការការវាយប្រហារដែលធ្វើឱ្យមានការខូចខាតនិងបាត់បង់ហេដ្ឋារចនាសម្ព័ន្ធនិងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ជាពិសេសទិន្នន័យ។ អគ្គនាយកដ្ឋានពន្ធដារ បាននិងកំពុងប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងសន្តិសុខព័ត៌មានស្តង់ដា ISO/IEC 27001:2013។ ស្របពេលដែលការវិវត្តនៃការប្រើប្រាស់ច្រើននូវហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងដើម្បីបន្តធានាបាននូវនិរន្តរភាព និងសន្តិសុខបច្ចេកវិទ្យាសម្រាប់រដ្ឋបាលសារពើពន្ធឌីជីថល អគ្គនាយកដ្ឋានពន្ធដារចាំបាច់ត្រូវដាក់ចេញនូវយុទ្ធសាស្ត្រ ដូចខាងក្រោម៖

យុទ្ធសាស្ត្រទី១៖ បន្តពង្រឹងប្រព័ន្ធគ្រប់គ្រងសន្តិសុខបច្ចេកវិទ្យាព័ត៌មាន

យុទ្ធសាស្ត្រទី២៖ បន្តពង្រឹងយន្តការស្តារ និងសង្គ្រោះទិន្នន័យ

## គោលបំណងទី៣៖ បន្តអភិវឌ្ឍមូលធនមនុស្ស និងពង្រឹងប្រសិទ្ធភាពការងារ

ការអភិវឌ្ឍមូលធនមនុស្ស និងការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តការងារ ត្រូវបានចាត់ទុកជាកិច្ចការអាទិភាពនៅក្នុងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា។ ការអភិវឌ្ឍមូលធនមនុស្ស ការពង្រឹងប្រសិទ្ធភាពការងារដោយមានយន្តការសវនកម្មផ្ទៃក្នុង និងការធានាតម្លាភាពនៃការចំណាយឱ្យស្របតាមផែនការយុទ្ធសាស្ត្រថវិកា គឺជាមូលដ្ឋានគ្រឹះក្នុងការអភិវឌ្ឍស្ថាប័នឱ្យមានសមត្ថភាពខ្ពស់ ដែលអាចឆ្លើយតបទាន់ពេលវេលាទៅនឹងបរិការណ៍សង្គម-សេដ្ឋកិច្ចឌីជីថល ដើម្បីពង្រឹងការគ្រប់គ្រងនិងការប្រមូលចំណូលពន្ធក្នុងស្រុកប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងកំណើនដោយចីរភាព។ ដើម្បីសម្រេចគោលបំណងនេះ អគ្គនាយកដ្ឋានពន្ធដារ កំណត់គោលដៅចំនួន ៣ ដូចតទៅ៖

## គោលដៅទី១៖ ពង្រឹងប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការគ្រប់គ្រងធនធានមនុស្ស

អគ្គនាយកដ្ឋានពន្ធដារបានផ្តល់អាទិភាពខ្ពស់លើការគ្រប់គ្រងនិងការកែទម្រង់ធនធានមនុស្ស ស្របតាម

ឧត្តមានុវត្តន៍អន្តរជាតិ។ លទ្ធផលនៃការកែទម្រង់ធនធានមនុស្សរបស់អគ្គនាយកដ្ឋានពន្ធដារបានចូលរួមចំណែកយ៉ាងសំខាន់នូវក្នុងការសម្រេចគោលដៅថវិកា និងការចូលរួមអនុវត្តដោយជោគជ័យ នូវកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រនានារបស់រាជរដ្ឋាភិបាល។ សមិទ្ធផលសំខាន់ៗដែលអគ្គនាយកដ្ឋានពន្ធដារសម្រេចបានមានជាអាទិ៍ ការរៀបចំរចនាសម្ព័ន្ធ យន្តការ និងវិធីសាស្ត្រ សម្រាប់គាំទ្រការគ្រប់គ្រងហានិភ័យផ្នែកធនធានមនុស្ស ដោយប្រើប្រាស់វិធីសាស្ត្រវាយតម្លៃ ISO 31000:2009 ការបង្កើតគណៈកម្មការគ្រប់គ្រងកម្មវិធីកែទម្រង់ផ្នែកធនធានមនុស្ស ការដាក់ចេញ និងអនុវត្តន៍នូវផែនការយុទ្ធសាស្ត្រធនធានមនុស្សជាបន្តបន្ទាប់ ការបង្កើតការិយាល័យសវនកម្មផ្ទៃក្នុង ការដាក់ឱ្យដំណើរការនូវប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស និងការពង្រឹងក្រមសីលធម៌មន្ត្រីរាជការពន្ធដារ។ ជាក់ស្តែង ស្ថាប័នអន្តរជាតិបានចាត់ទុកលទ្ធផលនៃការអនុវត្តកម្មវិធីកែទម្រង់ផ្នែកធនធានមនុស្សរបស់អគ្គនាយកដ្ឋានពន្ធដារ ជាការអនុវត្ត ដែលមានលក្ខណៈល្អប្រសើរ ឆ្លើយតប ឬលើសកម្រិតឧត្តមានុវត្តន៍អន្តរជាតិ។

ទោះជាយ៉ាងណាក៏ដោយ ការបន្តពង្រឹងប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការគ្រប់គ្រងធនធានមនុស្ស ឱ្យស្របតាមគោលនយោបាយ និងការរីកចម្រើននៃសង្គម-សេដ្ឋកិច្ចឌីជីថល គឺជាគោលដៅចម្បងរបស់អគ្គនាយកដ្ឋានពន្ធដារ សំដៅឆ្លើយតបតម្រូវការនៃការបន្តធ្វើទំនើបកម្មប្រតិបត្តិការទាំងមូលរបស់អគ្គនាយកដ្ឋានពន្ធដារ ទាំងមុខងារប្រតិបត្តិការស្នូល និងមុខងារគាំទ្រ និងជាពិសេស គឺការអភិវឌ្ឍសមត្ថភាព និងវិជ្ជាជីវៈពន្ធដាររបស់មន្ត្រីរាជការពន្ធដារគ្រប់រូប។ ដើម្បីសម្រេចគោលដៅនេះ អគ្គនាយកដ្ឋានពន្ធដារបានដាក់ចេញនូវយុទ្ធសាស្ត្រ ដូចខាងក្រោម៖

- យុទ្ធសាស្ត្រទី១៖ អភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងពង្រឹងសមត្ថភាពធនធានមនុស្ស
- យុទ្ធសាស្ត្រទី២៖ លើកកម្ពស់កិច្ចគាំពារមន្ត្រីរាជការពន្ធដារឱ្យមានលក្ខណៈជាប្រព័ន្ធ និងសមភាពយេនឌ័រ
- យុទ្ធសាស្ត្រទី៣៖ ពង្រឹងគុណភាពនៃប្រព័ន្ធគ្រប់គ្រងធនធានមនុស្សឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ
- យុទ្ធសាស្ត្រទី៤៖ ពង្រឹងក្រមសីលធម៌វិជ្ជាជីវៈ និងវិន័យមន្ត្រីរាជការពន្ធដារ
- យុទ្ធសាស្ត្រទី៥៖ ពង្រឹងរចនាសម្ព័ន្ធគ្រប់គ្រងរបស់អង្គភាព និងការធ្វើវិចារណកម្មមុខងារភារកិច្ច

## គោលដៅទី២៖ ពង្រឹងប្រសិទ្ធភាព និងសង្គតិភាពការងារ តាមរយៈសវនកម្មផ្ទៃក្នុង

មុខងារសវនកម្មផ្ទៃក្នុង គឺជាយន្តការគន្លឹះរបស់អគ្គនាយកដ្ឋានពន្ធដារ សម្រាប់តាមដានត្រួតពិនិត្យប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង ដើម្បីពង្រឹងប្រព័ន្ធអភិបាលកិច្ចស្ថាប័នក្នុងការផ្តល់សេវាសាធារណៈ សំដៅជំរុញការប្រមូលចំណូលពន្ធផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាព ដែលគាំទ្រដល់ការកែទម្រង់ដ៏ធាប់រហ័សរបស់អគ្គនាយកដ្ឋានពន្ធដារឱ្យកាន់តែមានសុក្រឹតភាព។ ជាក់ស្តែងក្នុងរយៈពេលប្រាំឆ្នាំកន្លងមក អគ្គនាយកដ្ឋានពន្ធដារបានខិតខំពង្រឹងការងារសវនកម្មផ្ទៃក្នុងឱ្យបានកាន់តែប្រសើរឡើង ដោយមានបទដ្ឋានរួមមួយកាន់តែច្បាស់លាស់

ជាងមុន ស្របតាមស្តង់ដាសវនកម្មផ្ទៃក្នុងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ អគ្គនាយកដ្ឋានពន្ធដារ បានយកចិត្តទុកដាក់យ៉ាងខ្ជាប់ខ្ជួនក្នុងការពង្រឹងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង តាមរយៈការដាក់ឱ្យអនុវត្ត និងវាយតម្លៃការអនុវត្តនិយាមនីតិវិធីប្រតិបត្តិការងារ និងពង្រឹងអនុលោមភាពរបស់រដ្ឋបាលសារពើពន្ធ ឱ្យស្របតាមអភិក្រមការងារក្រមសីលធម៌វិជ្ជាជីវៈពន្ធដារ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ បន្ថែមលើនេះ អគ្គនាយកដ្ឋានពន្ធដារបានដាក់ចេញនូវនិយាមនីតិវិធីប្រតិបត្តិការងារ (SOP) របស់គ្រប់អង្គភាពក្រោមឱវាទដែលត្រូវបានប្រើប្រាស់ជាឯកសារគោលសំខាន់ សម្រាប់ការងារត្រួតពិនិត្យនិងវាយតម្លៃ នៅក្នុងដំណើរការអនុវត្តន៍កិច្ចការសវនកម្មផ្ទៃក្នុង ពិនិត្យឱ្យឃើញនូវភាពខ្វះចន្លោះផ្សេងៗ និងផ្តល់អនុសាសន៍កែលម្អ ក្នុងគោលដៅពង្រឹងនិងពង្រីកសមត្ថភាពស្ថាប័នធនធានមនុស្ស និងអភិបាលកិច្ចល្អ ឱ្យកាន់តែមានប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព តម្លាភាព និងគណនេយ្យភាពបន្ថែមទៀត។

យ៉ាងណាមិញ អគ្គនាយកដ្ឋានពន្ធដារត្រូវបន្តពង្រឹងប្រសិទ្ធភាព និងសង្គតិភាពការងារតាមរយៈការអនុវត្តនូវមុខងារសវនកម្មផ្ទៃក្នុងយ៉ាងខ្ជាប់ខ្ជួន និងទទួលយកមតិកែលម្អពីស្ថាប័នខាងក្រៅ ដែលជាយន្តការត្រួតពិនិត្យនិងវាយតម្លៃលើការអនុវត្តផែនការកែលម្អតាមអនុសាសន៍សវនកម្មយ៉ាងហ្មត់ចត់ ផ្អែកតាមការកែលម្អជាចាំបាច់នូវចំណុចខ្វះខាតដែលបានរកឃើញកន្លងមក សំដៅធ្វើឱ្យប្រសើរឡើងនូវដំណើរការការងារនិងអនុលោមភាពរបស់រដ្ឋបាលសារពើពន្ធ និងក្រមសីលធម៌មន្ត្រីរាជការពន្ធដារ ផងដែរ។ ដើម្បីសម្រេចបាននូវគោលដៅនេះ អគ្គនាយកដ្ឋានពន្ធដារបានដាក់ចេញនូវយុទ្ធសាស្ត្រ ដូចខាងក្រោម៖

យុទ្ធសាស្ត្រទី១៖ ពង្រឹងប្រសិទ្ធភាព គុណភាព និងសុចរិតភាពការងារ

យុទ្ធសាស្ត្រទី២៖ ពង្រឹងអនុលោមភាពរដ្ឋបាលសារពើពន្ធ និងការអនុវត្តនិយាមនីតិវិធីប្រតិបត្តិការងារតាមរយៈការកែលម្អតាមអនុសាសន៍សវនកម្ម

## គោលដៅទី៣៖ ពង្រឹងប្រសិទ្ធភាព និងតម្លាភាពនៃការចំណាយ ឱ្យស្របតាមផែនការយុទ្ធសាស្ត្រថវិកា

ក្នុងរយៈពេលកន្លងមកនេះ អគ្គនាយកដ្ឋានពន្ធដារ ក្នុងនាមជាអង្គភាពថវិកាចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានចូលរួមអនុវត្តយ៉ាងសកម្មតាមគោលការណ៍ និងលិខិតបទដ្ឋានគតិយុត្តនានា សំដៅរួមចំណែកសម្រេចបានវឌ្ឍនភាពល្អក្នុងការងារកែទម្រង់ប្រព័ន្ធថវិកា និងការកសាងមូលដ្ឋានគ្រឹះសម្រាប់ត្រៀមឈានទៅអនុវត្តជំហានទី៤ គឺ "គណនេយ្យភាពសមិទ្ធកម្ម" ដែលជាដំណាក់កាលចុងក្រោយនៃកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈតាមរយៈការកំណត់យក **"ប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម"** ជាគំរូនៃការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជា ដែលគ្រោងនឹងដាក់ឱ្យអនុវត្តពេញលេញចាប់ពីឆ្នាំ២០២៥ ដើម្បីឆ្លើយតបទៅនឹងដំណាក់កាលថ្មី នៃការអភិវឌ្ឍប្រទេស ក៏ដូចជានិន្នាការថ្មីៗទាំងឡាយក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាអន្តរជាតិ។ ទន្ទឹមនឹងនេះ អគ្គនាយកដ្ឋានពន្ធដារតែងតែបានរៀបចំ និងអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ ដើម្បីឆ្លើយតបទៅនឹងអត្ថន័យ និងខ្លឹមសារទាំងស្រុងនៃកម្មវិធី

កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងយុទ្ធសាស្ត្រកៀរគរចំណូល ដែលកម្មវិធី និងយុទ្ធសាស្ត្រគោលទាំងពីរនេះ គឺជាវំហូរបែបប្រទាក់ក្រឡាគ្នាពីគោលនយោបាយកែទម្រង់ស៊ីជម្រៅថ្នាក់ជាតិនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល មកថ្នាក់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងចុះមកថ្នាក់អគ្គនាយកដ្ឋានពន្ធដារ។ ក្នុងរយៈពេលកន្លងទៅ ការកែទម្រង់ប្រព័ន្ធថវិកាកំពុងស្ថិតនៅលើមាគ៌ា និងទិសដៅត្រឹមត្រូវ ជាពិសេសការបោះជំហានឆ្ពោះទៅអនុវត្ត**ប្រព័ន្ធថវិកាកម្មវិធីពេញលេញ**ដែលការដាក់ឱ្យអនុវត្តនេះបាននាំមកនូវការកែប្រែការគ្រប់គ្រងថវិកាទាំងស្រុងពោលគឺពីប្រព័ន្ធគ្រប់គ្រងថវិកាផ្អែកលើធាតុចូល និងមជ្ឈការ ឆ្ពោះទៅប្រព័ន្ធថវិកាផ្អែកលើសមិទ្ធកម្ម និងវិមជ្ឈការ ទន្ទឹមនឹងការអនុញ្ញាតឱ្យរាជរដ្ឋាភិបាលបង្កើនប្រសិទ្ធភាពចំណាយនៃការវិភាជថវិកាឱ្យកាន់តែប្រសើរ ដោយបែរឆ្ពោះទៅរកវិស័យអាទិភាព។

ដើម្បីបន្តពង្រឹងប្រសិទ្ធភាព និងតម្លាភាពនៃការចំណាយឱ្យស្របតាមផែនការយុទ្ធសាស្ត្រថវិកា អគ្គនាយកដ្ឋានពន្ធដារបានដាក់ចេញនូវយុទ្ធសាស្ត្រដូចខាងក្រោម៖

យុទ្ធសាស្ត្រទី១៖ លើកកម្ពស់ស័ក្តិសិទ្ធិភាពនៃការរៀបចំថវិកាសមិទ្ធកម្មដែលត្រូវផ្តោតលើការសម្រេចលទ្ធផល

យុទ្ធសាស្ត្រទី២៖ ពង្រឹងប្រសិទ្ធភាពចំណាយឱ្យស្របតាមតម្រូវការអាទិភាពការងារ

# ផ្នែកទី៣
# សេចក្តីសន្និដ្ឋាន

ទន្ទឹមនឹងការសម្រេចបាននូវជោគជ័យ និងសមិទ្ធផលគួរជាទីមោទនៈក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រ ២០១៩-២០២៣ របស់អគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកដ្ឋានពន្ធដារនៅតែបន្តខិតខំយកចិត្តទុកដាក់ និងដាក់ចេញនូវកម្មវិធីកែទម្រង់ចាំបាច់ជាច្រើនក្នុងគោលបំណងបន្តពង្រឹងនិងលើកកម្ពស់គុណភាពសេវាអ្នកជាប់ពន្ធ ឱ្យបានសមស្របតាមការកើនឡើងឥតឈប់ឈរនៃតម្រូវការរបស់អ្នកជាប់ពន្ធ និងដើម្បីដោះស្រាយបញ្ហាប្រឈមនានាដែលកើតឡើងតាមរយៈការវិវត្តនៃសង្គម-សេដ្ឋកិច្ច និងបច្ចេកវិទ្យាឌីជីថល។

ផែនការយុទ្ធសាស្ត្រ ២០២៤-២០២៨ របស់អគ្គនាយកដ្ឋានពន្ធដារ គឺជាមគ្គុទេសក៍ និងជាផែនទីចង្អុលផ្លូវក្នុងការបន្តពង្រឹងការកែទម្រង់ស៊ីជម្រៅរបស់រដ្ឋបាលសារពើពន្ធ ក៏ដូចជាចូលរួមក្នុងការកែលម្អគោលនយោបាយសារពើពន្ធ ដើម្បីធ្វើទំនើបភាវូបនីយកម្មនៃអគ្គនាយកដ្ឋានពន្ធដារ និងសម្រេចឱ្យបានជោគជ័យនូវចក្ខុវិស័យ គោលបំណង គោលដៅ និងស្របតាមគោលនយោបាយនិងយុទ្ធសាស្ត្រនានា ដែលបានដាក់ចេញដោយរាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា។ ផែនការយុទ្ធសាស្ត្រនេះ នឹងប្រែក្លាយមុខមាត់ និងលើកកម្ពស់កិត្យានុភាពរបស់អគ្គ-នាយកដ្ឋានពន្ធដារមួយកម្រិតថែមទៀតទាំងក្នុងប្រទេស ក្នុងតំបន់ និងឆាកអន្តរជាតិ ក្នុងនាមជាស្ថាប័នសាធារណៈដែលត្រូវបានជឿជាក់ គោរព និងទទួលស្គាល់លើគុណភាព និងជំនាញក្នុងការប្រមូលចំណូលពន្ធដារ ដើម្បីជំរុញកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយចីរភាព។

ផែនការយុទ្ធសាស្ត្រ ២០២៤-២០២៨ របស់អគ្គនាយកដ្ឋានពន្ធដារ អាចសម្រេចទៅបានដោយជោគជ័យប្រសិនបើមានការចូលរួមអនុវត្តរួមគ្នានៅក្នុងអគ្គនាយកដ្ឋានពន្ធដារទាំងមូល ប្រកបដោយស្មារតីបុរេសកម្ម និងសកម្ម, ការគាំទ្រពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កិច្ចសហការពីគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធនិងអ្នកជាប់ពន្ធ, និងអាស្រ័យទៅតាមអំណោយផលនៃស្ថានភាព និងបរិយាកាសសម្រាប់រយៈពេល ៥ឆ្នាំ ដូចបានព្យាករទុក។ យ៉ាងណាមិញ ទាំងយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រនេះ អាចនឹងមិនសម្រេចបានជោគជ័យពេញលេញ ដែលអាចបណ្តាលមកពីកត្តាអវិជ្ជមាន ឬកត្តារាំងស្ទះជាច្រើនពុំអាចគ្រប់គ្រងបាន រួមមានដូចជា កង្វះខាតថវិកា បម្រែបម្រួលបរិយាកាសនយោបាយ ការកែប្រែនៃច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ និងបញ្ហាប្រធានសក្តិផ្សេងទៀតដែលអាចកើតឡើងទាំងក្នុងកម្រិតតំបន់និងពិភពលោក ដែលក្នុងនោះប្រទេសកម្ពុជាក៏ពុំអាចគេចផុតបាន ផងដែរ។



ចំណូលបានមកពីការបង់ពន្ធ
ត្រូវបានប្រើប្រាស់សម្រាប់
ការអភិវឌ្ឍលើគ្រប់វិស័យ
ការពារបូរណភាពទឹកដី
សាងសង់
• មន្ទីរពេទ្យ
• សាលារៀន
• ស្ពាន
• ថ្នល់
• ប្រព័ន្ធធារាសាស្ត្រ
ប្រាក់បៀវត្ស
• កងទ័ព
• នគរបាល
• គ្រូពេទ្យ
• គ្រូបង្រៀន
• មន្ត្រីរាជការ
ផ្តល់សេវាសាធារណៈ
• សុខាភិបាល
• អប់រំ
• សន្តិសុខសង្គម
• សណ្តាប់ធ្នាប់សាធារណៈ
គាំពារសង្គម
• ឧបត្ថម្ភគ្រួសារក្រីក្រ និងជនងាយរងគ្រោះ
ថវិកាបម្រុងសម្រាប់
គ្រោះអាសន្ន និងវិបត្តិ
សេដ្ឋកិច្ចផ្សេងៗ
សុខុមាលភាព
និងលើកកម្ពស់
សមភាពសង្គម